# អនុសញ្ញាអន្តរជាតិ ស្តីពី ការការពារជនគ្រប់រូបពី ការបាត់ខ្លួនដោយបង្ខំ



អង្គការសហប្រជាជាតិ

**សិទ្ធិមនុស្ស**

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ~ ការិយាល័យប្រចាំកម្ពុជា

# អនុសញ្ញាអន្តរជាតិ

# ស្តីពី

# ការការពារជនគ្រប់រូប

# ពីការបាត់ខ្លួនដោយបង្ខំ

ខែតុលា ឆ្នាំ២០១១

រូបភាពក្រប ដោយការិយាល័យ OHCHR នៅកម្ពុជា

នេះគឺជាការបោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការ
សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ

# មាតិកា

ទំព័រ

សេចក្តីផ្តើម ..............................................................៧

បុព្វកថា ..................................................................១១

ភាគ១ .....................................................................១២

ភាគ២ .....................................................................៣៥

ភាគ៣ .....................................................................៤៧

ឈឈ✦ឆឆ

# អនុសញ្ញាអន្តរជាតិ ស្តីពីការការពារ ជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ

## សេចក្តីផ្តើម

អនុសញ្ញាអន្តរជាតិ ស្តីពី ការការពារជនគ្រប់រូប ពីការបាត់ខ្លួនដោយបង្ខំ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីឆ្នាំ២០០៦ ហើយចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃ ២៣ ធ្នូ ២០១០ បន្ទាប់ពីការផ្តល់សច្ចាប័នចំនួន២០រដ្ឋ។ អនុសញ្ញានេះគឺជាលទ្ធផលនៃដំណើរការចរចារយៈពេល៣ឆ្នាំ ដែលមានការចូលរួមពីរដ្ឋជាង៧០ អង្គការក្រៅរដ្ឋាភិបាលជាច្រើន សមាគមគ្រួសារដែលមានសមាជិកបាត់ខ្លួនដោយបង្ខំ និងអ្នកជំនាញការជាច្រើនទៀត។ អនុសញ្ញានេះ តំនាងឲ្យការរីកចំរើនគួរឲ្យកត់សំគាល់នៅក្នុងច្បាប់អន្តរជាតិ ជាពិសេស ក្នុងការផ្តល់អត្ថន័យដល់ សិទ្ធិមិនត្រូវទទួលរងនូវការបាត់ខ្លួនដោយបង្ខំ ថាជាសិទ្ធិដែលមិនអាចព្យួរបាន។ នេះមានន័យថា ការបាត់ខ្លួនដោយបង្ខំ ត្រូវបានហាមឃាត់ដាច់ខាត ហើយសិទ្ធិនេះមិនត្រូវបានដាក់កំហិត ឬព្យួរឡើយ ទោះបីជាកាលៈទេសៈប្រទេសមានសង្គ្រាម ឬមានភាពអាសន្នក៏ដោយ។

ការបាត់ខ្លួនដោយបង្ខំ សំដៅដល់ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬទម្រង់ផ្សេងទៀតនៃការដកហូតសិទ្ធិធ្វើឡើងដោយភ្នាក់ងាររដ្ឋ ឬបុគ្គល ឬក្រុមបុគ្គលដែលមានការអនុញ្ញាត្តិ ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ លុះក្រោយមក បានបដិសេធមិនទទួលស្គាល់ពីការដកហូត

សេរីភាព ឬដោយមានការលាក់កំបាំងពីជោគវាសនា ឬទីកន្លែងជនបាត់ខ្លួន ដោយដាក់ជននោះឲ្យស្ថិតនៅក្រៅការការពារពីច្បាប់។

ការរីកដាល ឬការអនុវត្តន៍ជាប្រព័ន្ធ នៃការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់អន្តរជាតិ ដែលកំពុងអនុវត្តនិងត្រូវមានវិបាកដូចមានចែងក្នុងច្បាប់អន្តរជាតិជាធរមាន។

ការអនុវត្តន៍អនុសញ្ញានេះគ្មានករណីលើកលែងទេ ទោះរដ្ឋភាគីនោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ រាប់ទាំងប្រទេសស្ថិតក្នុងស្ថានភាពមានសង្គ្រាម ឬការគំរាមកំហែងដោយសង្គ្រាម អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពមានអាសន្នជាសាធារណៈណាក៏ដោយ មិនអាចយកមកធ្វើជាយុត្តិកម្មចំពោះការបាត់ខ្លួនដោយបង្ខំបានឡើយ។

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវចាត់វិធានការសមស្រប ដើម្បីធ្វើការស៊ើបអង្កេតពីអំពើល្មើសនេះ ហើយត្រូវនាំខ្លួនជនដែលប្រព្រឹត្តអំពើល្មើសនេះទៅផ្តន្ទាទោសនៅចំពោះមុខច្បាប់។

អនុសញ្ញានេះ ក៏ដូចជាសន្ធិសញ្ញាសិទ្ធិមនុស្សនានាដែរ បានបង្កើតស្ថាប័នសន្ធិសញ្ញាមួយ ដើម្បីតាមឃ្លាំមើលការអនុវត្តន៍អនុសញ្ញានេះ។ គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្កើតឡើង គឺជាស្ថាប័នរបស់អ្នកជំនាញការឯករាជ្យ សំរាប់តាមឃ្លាំមើលការអនុវត្តអនុសញ្ញានេះដោយរដ្ឋភាគី។ រដ្ឋភាគីទាំងអស់ ត្រូវដាក់របាយការណ៍ជាទៀងទាត់របស់ខ្លួនជូនគណៈកម្មាធិការនេះ ពីវិធានការនានាក្នុងការអនុវត្តន៍សិទ្ធិ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

ទន្ទឹមនឹងនោះ រដ្ឋភាគីត្រូវដាក់ជូនរបាយការណ៍បឋមរបស់ខ្លួន

ទៅគណៈកម្មាធិការ ២ឆ្នាំបន្ទាប់ពីបានផ្តល់សច្ចាប័ន។ គណៈកម្មាធិការនឹងពិនិត្យរបាយការណ៍នីមួយៗរបស់រដ្ឋភាគី និងផ្តល់ជាសំណើ ឬអនុសាសន៍ទូទៅលើរបាយការណ៍នោះ តាមតែខ្លួនយល់ថា សមស្រប ហើយបញ្ជូនទៅរដ្ឋភាគីសាមីវិញ។ គណៈកម្មាធិការ ជាទូទៅកោះប្រជុំរបស់ខ្លួននៅទីក្រុងហ្សឺណែវ ២ដងរៀងរាល់ឆ្នាំ។

បន្ទាប់ពីពិនិត្យមើលរបាយការណ៍ជាសកលតាមកាលកំណត់ (UPR) របស់កម្ពុជា កាលពីឆ្នាំ២០០៩ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ជាច្រើន ដែលរដ្ឋាភិបាលកម្ពុជាព្រមទទួលយកទាំងអស់ ក្នុងនោះក៏មានការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំដែរ។ កម្ពុជាត្រូវដាក់របាយការណ៍ជាសកលតាមកាលកំណត់ម្តងទៀត នៅឆ្នាំ២០១៣ ហើយត្រូវរាយការណ៍ពីការរីកចំរើនលើវិស័យសិទ្ធិមនុស្សរបស់ខ្លួន រួមទាំងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនានាផង ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ<br>
ទទួលបន្ទុកសិទ្ធិមនុស្ស<br>
ការិយាល័យប្រចាំនៅកម្ពុជា<br>
ខែកញ្ញា ឆ្នាំ២០១១

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# ការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ

## បុព្វកថា

***រដ្ឋភាគីនៃអនុសញ្ញានេះ***

*ពិចារណាអំពី*កាតព្វកិច្ចរបស់រដ្ឋភាគី តាមធម្មនុញ្ញសហប្រជាជាតិ ដើម្បីលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

*ដោយយកចិត្តទុកដាក់ចំពោះ* សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស

*រំលឹកឡើងវិញ*អំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធដទៃទៀត នៅក្នុងវិស័យសិទ្ធិមនុស្ស ច្បាប់មនុស្សធម៌ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

*រំលឹកឡើងវិញផងដែរ* អំពីសេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៤៧/១៣៣ ចុះថ្ងៃ ១៨ ខែធ្នូ ឆ្នាំ១៩៩២ ។

*ដោយដឹងអំពី* ភាពធ្ងន់ធ្ងរបំផុតនៃការបាត់ខ្លួនដោយបង្ខំ ដែល-បង្កើតបានជាបទឧក្រិដ្ឋមួយ និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុង-កាលៈទេសៈមួយចំនួនដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ ។

*ដោយបានប្តេជ្ញាចិត្ត* ដើម្បីបង្ការការបាត់ខ្លួនដោយបង្ខំ និងដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្ម នៃការបាត់ខ្លួនដោយបង្ខំ

*ដោយពិចារណាអំពី* សិទ្ធិបុគ្គលគ្រប់រូប ដែលមិនត្រូវស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ សិទ្ធិជនរងគ្រោះក្នុងការទាមទារយុត្តិធម៌ និងសំណងជម្ងឺចិត្ត ។

*បញ្ជាក់អំពី* សិទ្ធិជនរងគ្រោះ ត្រូវដឹងការពិតពីកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ និងអំពីជោគវាសនានៃជនបាត់ខ្លួន និងសិទ្ធិមានសេរីភាពស្វែងរក ទទួល និងចែករំលែកព័ត៌មានក្នុងគោលបំណងនេះ ។

*បានព្រមព្រៀងលើមាត្រាទាំងឡាយដូចខាងក្រោមនេះ :*

## ភាគ ១

### *មាត្រា ១ :*

គ្មានជនណាម្នាក់ ត្រូវស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំឡើយ ។

គ្មានករណីលើកលែង ទោះជាក្នុងករណីណាក៏ដោយ ទោះជាក្នុងស្ថានភាពសង្គ្រាម ឬការគំរាមកំហែងដោយសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នជាសាធារណៈណាក៏ដោយ មិនអាចយកជាយុត្តិកម្មចំពោះការបាត់ខ្លួនដោយបង្ខំឡើយ ។

### មាត្រា ២ :

សំរាប់គោលបំណងនៃអនុសញ្ញានេះ "ការបាត់ខ្លួនដោយបង្ខំ"សំដៅដល់ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬទម្រង់ផ្សេងទៀតនៃការដកហូតសិទ្ធិ ធ្វើឡើងដោយភ្នាក់ងាររដ្ឋ ឬដោយបុគ្គល ឬដោយក្រុមបុគ្គលដែលមានការអនុញ្ញាត ការគាំទ្រឬការយល់ព្រមពីរដ្ឋ លុះក្រោយមកបានបដិសេធមិនទទួលស្គាល់ពីការដកហូតសេរីភាព ឬដោយមានការលាក់បំបាំងពីជោគវាសនា ឬទីកន្លែងជនបាត់ខ្លួន ដោយដាក់ជននោះឱ្យស្ថិតនៅក្រៅការការពារពីច្បាប់ ។

### មាត្រា ៣ :

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្របដើម្បីស៊ើបអង្កេតអំពើល្មើសដែលមានចែងក្នុងមាត្រា២ ដែលបានប្រព្រឹត្តដោយបុគ្គល ឬដោយក្រុមបុគ្គលដែលគ្មានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ហើយត្រូវនាំខ្លួនជនដែលទទួលខុសត្រូវទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

### មាត្រា ៤ :

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាថា ការបាត់ខ្លួនដោយបង្ខំ គឺជាបទល្មើសមួយតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។

### មាត្រា ៥ :

ការរីកដាល ឬការអនុវត្តន៍ជាប្រព័ន្ធនៃការបាត់ខ្លួនដោយបង្ខំ គឺ

ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់អន្តរជាតិ ដែលកំពុងអនុវត្ត និងត្រូវមានវិបាកដូចមានចែងក្នុងច្បាប់អន្តរជាតិជាធរមាន។

***មាត្រា ៦ :***

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីចាប់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ យ៉ាងហោចណាស់ចំពោះៈ

(ក).ជនណាក៏ដោយដែលប្រព្រឹត្ត បញ្ជា ស្នើសុំ ឬញុះញង់ឱ្យប្រព្រឹត្ត ប៉ុនប៉ង់ប្រព្រឹត្ត គឺជាអ្នកសមគំនិត ឬចូលរួមក្នុងការបាត់ខ្លួនដោយបង្ខំ។

(ខ). អ្នកគ្រប់គ្រងដែល :

(i). បានដឹង ឬមានចេតនាមិនអើពើចំពោះព័ត៌មានដែលបានបញ្ជាក់ច្បាស់លាស់ថា អ្នកក្រោមបង្គាប់ ដែលស្ថិតក្រោមអំណាច និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្លួន កំពុងប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តបទឧក្រិដ្ឋ នៃការបាត់ខ្លួនដោយបង្ខំ

(ii). បានអនុវត្តការទទួលខុសត្រូវ និងការគ្រប់គ្រង ដ៏មានប្រសិទ្ធភាព ចំពោះសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ និង

(iii). មិនបានចាត់រាល់វិធានការចាំបាច់ និងសមហេតុផល ក្នុងដែនអំណាចរបស់ខ្លួន ដើម្បីបង្ការ ឬបង្ក្រាបការប្រព្រឹត្តបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ ឬបញ្ជូនបញ្ហានេះ ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការស៊ើបអង្កេត និងផ្តន្ទាទោស

(គ).អនុកថាខ័ណ្ឌ(ខ)ខាងលើ មិនធ្វើឱ្យប៉ះពាល់ដល់ក៏រិតនៃការទទួលខុសត្រូវខ្ពស់ជាង ដែលកំពុងអនុវត្តក្រោមច្បាប់អន្តរជាតិ ចំពោះមេបញ្ជាការយោធា ឬចំពោះបុគ្គលដែលកំពុងដើរតួនាទី យ៉ាងមានប្រសិទ្ធភាពដូចជាមេបញ្ជាការយោធានោះទេ។

(២) គ្មានបញ្ជា ឬការណែនាំពីអាជ្ញាធរសាធារណៈណាមួយ ជនស៊ីវិល យោធា ឬអ្នកដទៃទៀតអាចត្រូវបានលើកមកធ្វើការដោះសារ ដើម្បីធ្វើយុត្តិកម្មពីបទល្មើសនៃការបាត់ខ្លួនដោយបង្ខំឡើយ។

## *មាត្រា ៧ :*

រដ្ឋភាគីនីមួយៗ ត្រូវដាក់បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ អោយមានការផ្តន្ទាទោសដោយទោសបញ្ញត្តិ សមស្រប ដោយពិចារណាទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស។

រដ្ឋភាគីនីមួយៗ អាចបង្កើត :

(ក) ស្ថានសំរាលទោសបាន ជាពិសេសចំពោះជនដែលត្រូវធ្វើឱ្យមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ នៃការបាត់ខ្លួនដោយបង្ខំ ហើយដែលរួមវិភាគទានដ៏មានប្រសិទ្ធភាពក្នុងការនាំខ្លួនជនបាត់ខ្លួនឱ្យរស់រានមានជីវិត ឬផ្តល់លទ្ធភាពដល់ការបំភ្លឺករណី នៃការបាត់ខ្លួនដោយបង្ខំ ឬដើម្បីកំណត់អត្តសញ្ញាណជនល្មើសនៃការបាត់ខ្លួនដោយបង្ខំ។

(ខ) ស្ថានទម្ងន់ទោសដោយមិនធ្វើឱ្យខូចខាតដល់នីតិវិធីព្រហ្មទណ្ឌដទៃទៀត ជាពិសេសក្នុងករណីនៃការស្លាប់របស់ជនបាត់ខ្លួន ឬការប្រព្រឹត្ត

បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ចំពោះស្ត្រីមានផ្ទៃពោះ អនីតិជន ជនពិការ ឬក៏ជនដែលងាយរងគ្រោះជាពិសេសផ្សេងទៀត ។

## មាត្រា ៨ :

ដោយមិនធ្វើឱ្យខូចខាតដល់មាត្រា៥ :

រដ្ឋភាគីនីមួយៗ ដែលអនុវត្តអាជ្ញាយុកាលចំពោះការបាត់ខ្លួន ដោយបង្ខំ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា រយៈពេលអាជ្ញាយុកាល សំរាប់នីតិវិធីព្រហ្មទណ្ឌត្រូវ :

(ក). មានរយៈពេលវែង និងមានសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនោះ

(ខ). គិតចាប់ពីពេលដែលបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ បានបញ្ចប់ ដោយធ្វើការពិចារណាអំពីចរិតបន្តរបស់វា ។

រដ្ឋភាគីនីមួយៗ ត្រូវធានាការពារសិទ្ធិជនរងគ្រោះ ដោយការបាត់ខ្លួនដោយបង្ខំ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងអំឡុងពេលនៃអាជ្ញាយុកាលនេះ ។

## មាត្រា ៩ :

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីកំណត់ពីសមត្ថកិច្ចរបស់ខ្លួន ក្នុងការអនុវត្តនីយុត្តាធិការលើបទល្មើសនៃការបាត់ខ្លួន ដោយបង្ខំ :

(ក) នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីណាមួយក្រោមយុត្តាធិការរបស់ខ្លួន ឬនៅលើនាវា ឬយន្តហោះដែលបានចុះបញ្ជី ក្នុងរដ្ឋនោះ

(ខ) នៅពេលដែលជនល្មើសដែលជាប់ចោទ គឺជាជនជាតិរបស់ខ្លួន

(គ) នៅពេលដែលជនបាត់ខ្លួន គឺជាជនជាតិរបស់ខ្លួន ហើយរដ្ឋភាគី យល់ថា វាជាការសមស្រប ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការដូចគ្នានេះដែរតាមការចាំបាច់ ដើម្បីកំណត់សមត្ថកិច្ចរបស់ខ្លួន ក្នុងការអនុវត្តនីយុត្តាធិការលើបទល្មើស នៃការបាត់ខ្លួនដោយបង្ខំ នៅពេលជនល្មើសដែលជាប់ចោទ មានវត្តមាននៅលើទឹកដីណាមួយ ក្រោមយុត្តាធិការរបស់ខ្លួន បើពុំនោះទេ រដ្ឋភាគីនោះត្រូវធ្វើបត្យាប័ន ឬប្រគល់ជនល្មើសនោះទៅឱ្យរដ្ឋមួយទៀត ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬប្រគល់ជនល្មើសនោះឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិដែលរដ្ឋនោះបានទទួលស្គាល់ពីយុត្តាធិការតុលាការនេះ ។

៣. អនុសញ្ញានេះ មិនបានផាត់ចោលយុត្តាធិការព្រហ្មទណ្ឌបន្ថែមណាមួយ ដែលបានអនុវត្តស្របតាមច្បាប់ជាតិឡើយ ។

### *មាត្រា ១០ :*

១. បន្ទាប់ពីយល់ថាគ្រប់គ្រាន់ល្មមហើយនោះ ក្រោយពីការពិនិត្យព័ត៌មានដែលរដ្ឋនោះមាន ថាករណីនេះជាការចាំបាច់ រដ្ឋភាគីណាក៏ដោយនៅលើទឹកដីរបស់ខ្លួន ត្រូវចាប់ឃុំជនដែលត្រូវសង្ស័យថាបានប្រព្រឹត្តបទល្មើស

នៃការបាត់ខ្លួនដោយបង្ខំ ឬចាត់វិធានការតាមផ្លូវច្បាប់តាមការចាំបាច់ ដើម្បីអះអាងពីវត្តមានជននោះ។ ការឃុំខ្លួន និងវិធានការតាមផ្លូវច្បាប់ដទៃទៀតត្រូវតែអនុវត្តដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីនោះ ប៉ុន្តែអាចឃុំខ្លួនបានក្នុងរយៈពេលមួយចាំបាច់តែប៉ុណ្ណោះ ដើម្បីធានាវត្តមានជនសង្ស័យតាមនីតិវិធីព្រហ្មទណ្ឌ ការប្រគល់ ឬការធ្វើបត្យាប័ន។

២. រដ្ឋភាគីដែលបានចាត់វិធានការ ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវធ្វើការសាកសួរ ឬការស៊ើបអង្កេតជាបឋមភ្លាមៗ ដើម្បីកំណត់អង្គហេតុ។ រដ្ឋភាគីនេះ ត្រូវជូនដំណឹងទៅរដ្ឋភាគីដទៃទៀត ដូចមានចែងក្នុងមាត្រា៩ កថាខ័ណ្ឌ១ អំពីការចាត់វិធានការរបស់ខ្លួន ស្របតាមកថាខ័ណ្ឌ១ នៃមាត្រានេះ រួមទាំងការឃុំខ្លួន និងករណីដែលតម្រូវឱ្យមានការឃុំខ្លួន និងរបាយការណ៍ស្តីពីការសាកសួរ ឬការស៊ើបអង្កេតបឋមរបស់ខ្លួនដោយបញ្ជាក់ថាតើ ខ្លួនមានបំណងអនុវត្តយុត្តាធិការរបស់ខ្លួនឬទេ។

៣. ជនជាប់ឃុំឃាំង ស្របតាមកថាខ័ណ្ឌ១នៃមាត្រានេះ អាចទាក់ទងភ្លាមៗ ជាមួយតំណាងសមស្របដែលនៅជិតបំផុតនៃរដ្ឋដែលខ្លួនជាជន-ជាតិ ឬប្រសិនជាជននោះជាជនគ្មានសញ្ជាតិ គាត់អាចទាក់ទងជាមួយតំណាងរដ្ឋ ដែលខ្លួនរស់នៅជាធម្មតា។

### ***មាត្រា ១១ :***

១. រដ្ឋភាគីដែលលើទឹកដីក្រោមយុត្តាធិការរបស់ខ្លួន មានជនណាម្នាក់ ត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ បើខ្លួនមិនធ្វើបត្យាប័ន ឬប្រគល់ជននោះទៅឱ្យរដ្ឋណាមួយ ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬមិនប្រគល់ជននោះឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិដែលខ្លួនបានទទួលស្គាល់សមត្ថកិច្ចតុលាការនោះទេ ត្រូវបញ្ជូនករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។

២. អាជ្ញាធរទាំងនេះ ត្រូវធ្វើការសំរេចរបស់ខ្លួន ក្នុងលក្ខណៈដូចគ្នាទៅនឹងករណីនៃបទល្មើសធម្មតា ដែលមានចរិតធ្ងន់ធ្ងរ ក្រោមច្បាប់រដ្ឋភាគីនោះ ។ ក្នុងករណីដូចមានចែងក្នុងមាត្រា៩ កឋាខ័ណ្ឌ២ បទដ្ឋាននៃភស្តុតាងដែលតម្រូវឱ្យមាន សំរាប់ការចោទប្រកាន់ និងការផ្តន្ទាទោស មិនត្រូវឱ្យស្រាលជាង បទដ្ឋាននៃភស្តុតាងដែលអនុវត្តក្នុងករណីទាំងឡាយដែលមាន-ចែងក្នុងមាត្រា៩ កឋាខ័ណ្ឌ១ ឡើយ ។

៣. ជនណាម្នាក់ដែលត្រូវគេចាត់នីតិវិធីប្រឆាំងមកលើខ្លួន ពាក់ព័ន្ធនឹងបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវបានធានាការពារឱ្យមានការប្រព្រឹត្តមកលើខ្លួនឱ្យបានត្រឹមត្រូវ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។ ជនណាម្នាក់ ដែលត្រូវបានជំនុំជំរះ ក្នុងបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវទទួលបានអត្ថប្រយោជន៍ពីការជំនុំជំរះដោយយុត្តិធម៌នៅចំពោះមុខសាលាជំរះក្តីមួយដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ឬតុលាការដែលបានបង្កើតឡើងដោយច្បាប់ ។

***មាត្រា ១២ :***

១. រដ្ឋភាគីនីមួយៗ ត្រូវធានាថា ជនណាក៏ដោយដែលចោទថា ជនណាម្នាក់ ត្រូវបានស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ មានសិទ្ធិរាយការណ៍អំពីអង្គហេតុនោះ ទៅអាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវពិនិត្យលើការចោទប្រកាន់នោះជាបន្ទាន់ និងដោយមិនលំអៀង ហើយប្រសិនជាចាំបាច់ ត្រូវធ្វើការស៊ើបអង្កេតទាំងស្រុង និងមិនលំអៀងមួយ ដោយគ្មានការពន្យាពេល។ ត្រូវចាត់វិធានការសមស្របប្រសិនជាចាំបាច់ ដើម្បីធានាថាដើមចោទ សាក្សី សាច់ញាតិជនបាត់ខ្លួនដោយបង្ខំ និងមេធាវីរបស់គេ ព្រមទាំងបុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបអង្កេត ត្រូវបានការពារ ប្រឆាំងនឹងរាល់ការព្យាបាទ ឬការបំភិតបំភ័យ ដោយសារតែការប្តឹង ឬការផ្តល់ភស្តុតាងណាមួយឡើយ។

២. ប្រសិនជាមានហេតុផលសមស្របអាចជឿថា បុគ្គលម្នាក់ កំពុងស្ថិតក្នុងការបាត់ខ្លួនដោយបង្ខំ អាជ្ញាធរ ដែលមានចែងក្នុងកឋាខ័ណ្ឌ១ នៃ-មាត្រានេះ ត្រូវធ្វើការស៊ើបអង្កេត បើទោះជាមិនមានបណ្តឹងជាផ្លូវការក៏ដោយ។

រដ្ឋភាគីនីមួយៗ ត្រូវធានាថា អាជ្ញាធរទាំងឡាយដែលមានចែងក្នុងកឋាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវ :

(ក) មានអំណាច និងធនធានចាំបាច់ ដើម្បីធ្វើការស៊ើបអង្កេតអោយមានប្រសិទ្ធភាព រួមទាំងសិទ្ធិប្រើប្រាស់សំណុំឯកសារ និងព័តិមានផ្សេងៗ ពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ខ្លួន។

(ខ) ប្រសិនជាចាំបាច់ ដោយមានការអនុញ្ញាតជាមុន ពីអាជ្ញាធរតុលាការ ដែលត្រូវសំរេចពីបញ្ហានេះជាបន្ទាន់ មានសិទ្ធិចូលទៅទីកន្លែងឃុំឃាំង ឬកន្លែងដទៃណាក៏ដោយ ដែលមានហេតុផលសមស្របអោយជឿបានថា ជនបាត់ខ្លួនមានវត្តមាននៅទីនោះ ។

៤. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងដាក់ទណ្ឌកម្មទង្វើទាំងឡាយ ដែលបង្កឧបសគ្គ ដល់ដំណើរការស៊ើបអង្កេត ។ រដ្ឋភាគីត្រូវធានាជាពិសេសថាជនសង្ស័យដែលបានប្រព្រឹត្តបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ មិនមានតួនាទីជ្រៀតជ្រែក ដល់កិច្ចដំណើរការស៊ើបអង្កេតដោយមធ្យោបាយគាបសង្កត់ ឬការបំភិតបំភ័យ ឬការសងសឹកចំពោះដើមចោទ សាក្សី សាច់ញាតិជនបាត់ខ្លួន ឬមេធាវីរបស់ខ្លួន ឬចំពោះបុគ្គលដែលចូលរួមក្នុងការស៊ើបអង្កេត ។

## *មាត្រា ១៣ :*

សំរាប់គោលបំណងនៃការធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ មិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយឬបទល្មើសពាក់ព័ន្ធនឹងរឿងនយោបាយ ឬបទល្មើសណាមួយ ដែលបានឃុបឃិតក្នុងគោលបំណងនយោបាយ ។ អាស្រ័យហេតុនេះការស្នើធ្វើបត្យាប័នដោយផ្អែកលើបទល្មើសបែបនេះ មិនអាចត្រូវបានបដិសេធ ដោយផ្អែកតែលើមូលហេតុនេះមួយមុខបានឡើយ ។

២. បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវចាត់ថា បានរាប់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាន នៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយ

រវាងរដ្ឋភាគី នៅមុនការចូលជាធរមាននៃអនុសញ្ញានេះ ។

៣. រដ្ឋភាគីត្រូវបញ្ចូលបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ថាជាបទល្មើសមួយ ដែលអាចធ្វើបត្យាប័នបាន នៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលក្រោយមក ត្រូវបានធ្វើឡើងរវាងរដ្ឋភាគីទាំងនោះ ។

៤.ប្រសិនបើរដ្ឋភាគីមួយដែលកំណត់លក្ខខណ្ឌបត្យាប័នលើអត្ថិភាពនៃសន្ធិសញ្ញាមួយ ទទួលការស្នើសុំធ្វើបត្យាប័នពីរដ្ឋភាគីមួយទៀត ដែលមិនមានសន្ធិសញ្ញាបត្យាប័ន រដ្ឋនោះអាចចាត់ទុកអនុសញ្ញានេះថាជាមូលដ្ឋានគតិយុត្តិចាំបាច់សំរាប់ការធ្វើបត្យាប័នចំពោះបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ។

៥. រដ្ឋភាគីដែលមិនកំណត់លក្ខខណ្ឌបត្យាប័ន លើអត្ថិភាពនៃសន្ធិសញ្ញាមួយ ត្រូវទទួលស្គាល់បទល្មើសនៃការបាត់ខ្លួនដោយបង្ខំថាជាបទល្មើសមួយដែលអាចធ្វើបត្យាប័នបានរវាងរដ្ឋភាគី ។

៦. នៅគ្រប់ករណីទាំងអស់ ការធ្វើបត្យាប័នត្រូវស្ថិតក្រោមលក្ខខណ្ឌ ដែលមានចែងដោយច្បាប់របស់រដ្ឋភាគី ដែលបានស្នើសុំធ្វើបត្យាប័ន ឬដោយសន្ធិសញ្ញាបត្យាប័ននានាដែលកំពុងអនុវត្ត ជាពិសេសរួមទាំងលក្ខខណ្ឌទាក់ទងនឹងការទាមទារទោសបញ្ញត្តិជាអប្បបរមា សំរាប់ការធ្វើបត្យាប័ន និងមូលហេតុរដ្ឋភាគីដែលបានស្នើសុំធ្វើបត្យាប័ន អាចបដិសេធការធ្វើបត្យាប័ន ឬកំណត់ឱ្យវាស្ថិតក្រោមលក្ខខណ្ឌមួយចំនួន ។

៧. គ្មានបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ត្រូវបានធ្វើការបកស្រាយថា ជាការកំណត់កាតព្វកិច្ចចំពោះការធ្វើបត្យាប័នឡើយ ប្រសិនបើរដ្ឋភាគី

ដែលស្នើសុំធ្វើបត្យាប័ន មានហេតុផលរឹងមាំដែលអាចជឿថាការស្នើសុំនោះ បានធ្វើឡើងក្នុងគោលបំណងធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសជនណាម្នាក់ ដោយមូលហេតុនៃភេទ ពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិ មតិនយោបាយ ឬសមាជិកភាពនៃក្រុមសង្គមណាមួយ ឬថាការអនុវត្តន៍តាមការស្នើសុំ អាចនឹងបង្កអន្តរាយដល់ជននោះចំពោះហេតុផលណាមួយក្នុងចំណោមហេតុផលទាំងនោះ ។

## មាត្រា ១៤ :

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមក នូវវិធានការមានប្រសិទ្ធភាពបំផុត តាមជំនួយផ្លូវច្បាប់ពាក់ព័ន្ធនឹងចំណាត់ការព្រហ្មទណ្ឌ ចំពោះបទល្មើសនៃការបាត់ខ្លួនដោយបង្ខំដោយរួមទាំងការផ្តល់ភស្តុតាងគ្រប់បែបយ៉ាងដែលចាំបាច់ តាមធនធានរបស់ខ្លួន សំរាប់ដំណើរការនីតិវិធី ។

២. ការជួយគ្នាទៅវិញទៅមក តាមផ្លូវច្បាប់នេះ ត្រូវស្ថិតក្រោមលក្ខខណ្ឌដែលមានចែងដោយច្បាប់ក្នុងស្រុក នៃរដ្ឋភាគីដែលបានស្នើសុំធ្វើបត្យាប័ន ឬដោយសន្ធិសញ្ញានានាស្តីពីជំនួយផ្នែកច្បាប់ដែលកំពុងអនុវត្ត ជាពិសេសរួម ទាំងលក្ខខណ្ឌទាក់ទងនឹងមូលហេតុ ដែលរដ្ឋភាគីស្នើសុំធ្វើបត្យាប័នអាចបដិសេធមិនផ្តល់ជំនួយតាមផ្លូវច្បាប់ ឬអាចកំណត់លក្ខខណ្ឌផ្សេងៗ។

## មាត្រា ១៥ :

១. រដ្ឋភាគី ត្រូវសហការគ្នា ហើយត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកនូវវិធានការមានប្រសិទ្ធភាពបំផុត ក្នុងការជួយគ្នាទៅវិញទៅមក ក្នុងគោល

បំណងជួយជនរងគ្រោះ ដោយការបាត់ខ្លួនដោយបង្ខំ និងក្នុងការស្វែងរកការកំណត់ទីកន្លែង និងការដោះលែងជនបាត់ខ្លួន ហើយក្នុងករណីជនរងគ្រោះទទួលមរណៈភាព ត្រូវគាស់សាកសព និងកំណត់អត្តសញ្ញាណ ហើយត្រូវបញ្ជូនធាតុទៅប្រទេសរបស់គេវិញ ។

## *មាត្រា ១៦ :*

១. គ្មានរដ្ឋភាគីណាមួយ ត្រូវនិរទេស បញ្ជូនត្រឡប់មកវិញ (“refouler”) ប្រគល់ ឬធ្វើបត្យាប័នជនណាម្នាក់ ទៅឱ្យរដ្ឋណាមួយទៀត ដែលមានហេតុផលរឹងមាំអាចជឿថា ជននោះនឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដោយការបាត់ខ្លួនដោយបង្ខំឡើយ ។

២. សំរាប់គោលបំណងនៃការកំណត់ពីហេតុផលទាំងនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិចារណាអំពីករណីពាក់ព័ន្ធ ប្រសិនជាអាចធ្វើទៅបាន រួមទាំងអំពីអត្ថិភាពក្នុងរដ្ឋសាមី នូវលំនាំពាក់ព័ន្ធនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាក់ស្តែង ឬទ្រង់ទ្រាយធំ ឬអំពីការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ។

## *មាត្រា ១៧ :*

គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនក្នុងមន្ទីរឃុំឃាំងសំងាត់ឡើយ ។

ដោយមិនធ្វើឱ្យប៉ះពាល់ដល់ កាតព្វកិច្ចអន្តរជាតិដទៃទៀត នៃរដ្ឋភាគី ចំពោះការដកហូតសេរីភាព រដ្ឋភាគីនីមួយៗ ត្រូវចែងក្នុងច្បាប់របស់ខ្លួន នូវការ :

(ក) បង្កើតលក្ខខណ្ឌ ដែលតាមរយៈនោះ អាចចេញបញ្ជាឱ្យដក ហូតសេរីភាព

(ខ) បញ្ជាក់ថា អាជ្ញាធរទាំងនោះ ត្រូវបានអនុញ្ញាតឱ្យចេញបញ្ជា ដកហូតសេរីភាព

(គ) ធានាថា ជនដែលត្រូវគេដកហូតសេរីភាព ត្រូវបានឃុំខ្លួន តែនៅក្នុងកន្លែងដកហូតសេរីភាព ដែលមានការគ្រប់គ្រង និងទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះ។

(ឃ) ធានាថា ជនដែលត្រូវគេដកហូតសេរីភាព ត្រូវបានអនុញ្ញាតឱ្យធ្វើការទាក់ទងជាមួយ និងត្រូវបានទទួលការសួរសុខទុក្ខពីគ្រួសារ មេធាវីឬអ្នកដទៃទៀត តាមការជ្រើសរើសរបស់ខ្លួន អនុលោមតាមលក្ខខណ្ឌដែលច្បាប់កំណត់ ឬប្រសិនបើជននោះ ជាជនបរទេស អាចទាក់ទងជាមួយអាជ្ញាធរកុងស៊ុលរបស់ខ្លួន ស្របតាមច្បាប់អន្តរជាតិ ជាធរមាន។

(ង) ធានាថា អាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ចស្របច្បាប់ ដែលមានការអនុញ្ញាត អាចចូលទៅដល់កន្លែងដាក់ជនដែលត្រូវគេដកហូតសេរីភាព ប្រសិនជាចាំបាច់ ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរតុលាការ។

(ច) ធានាថាជនដែលត្រូវគេដកហូតសេរីភាព ឬក្នុងករណីសង្ស័យថាមានការបាត់ខ្លួនដោយបង្ខំ ដោយសារជនដែលត្រូវគេដកហូតសេរីភាព មិនអាចប្រើប្រាស់សិទ្ធិនេះ ជនដែលមានផលប្រយោជន៍ស្របច្បាប់ ដូចជាសាច់ញាតិ នៃជនដែលត្រូវគេដកហូតសេរីភាព តំណាង ឬមេធាវីរបស់ខ្លួន នៅគ្រប់ករណីទាំងអស់ ត្រូវមានសិទ្ធិធ្វើចំណាត់ការតាមផ្លូវច្បាប់ នៅចំពោះ

មុខតុលាការ ដើម្បីឱ្យតុលាការសំរេចដោយមិនមានការពន្យារពេល អំពីភាពស្របច្បាប់ នៃការដកហូតសេរីភាព និងដើម្បីធ្វើការដោះលែងជននោះ ប្រសិនបើការដកហូតសេរីភាពនេះ ខុសច្បាប់ ។

៣. រដ្ឋភាគីនីមួយៗ ត្រូវធានាពីការចងក្រង និងការរក្សាបញ្ជីផ្លូវការមួយ ឬច្រើន ដែលបានធ្វើបច្ចុប្បន្នភាព និង/ឬកំណត់ហេតុជន ដែលត្រូវបានដកហូតសេរីភាព ដែលត្រូវរកអោយបានភ្លាមៗ តាមការស្នើសុំ ដល់អាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ចដទៃទៀត ដែលបានអនុញ្ញាតសំរាប់គោលបំណងនោះ ដោយច្បាប់នៃរដ្ឋភាគីសាមុី ឬដោយលិខិតុបករណ៍គតិយុត្តិអន្តរជាតិណាមួយពាក់ព័ន្ធ ដែលរដ្ឋសាមុីជាភាគី។ ព័ត៌មាននៅក្នុងនោះ ត្រូវមានជាអប្ប បរមានូវ :

(ក) អត្តសញ្ញាណរបស់ជនដែលត្រូវគេដកហូតសេរីភាព

(ខ) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលជននោះត្រូវគេដកហូតសេរីភាព និងអត្តសញ្ញាណអាជ្ញាធរដែលបានដកហូតសេរីភាពជននោះ

(គ) អាជ្ញាធរដែលបានបញ្ជាឱ្យដកហូតសេរីភាព និងមូលហេតុ នៃការដកហូតសេរីភាព

(ឃ) អាជ្ញាធរទទួលខុសត្រូវគ្រប់គ្រងការដកហូតសេរីភាព

(ង) កន្លែងដកហូតសេរីភាព កាលបរិច្ឆេទ និងពេលវេលានៃការ-ដាក់ចូលកន្លែងដកហូតសេរីភាព និងអាជ្ញាធរ ទទួលខុសត្រូវកន្លែងដកហូតសេរីភាព

(ច) សមាសធាតុទាក់ទងនឹងស្ថានភាពសុខភាព របស់ជនដែលត្រូវគេដកហូតសេរីភាព

(ឆ) ក្នុងករណីមរណៈភាព ក្នុងអំឡុងពេលនៃការដកហូតសេរី-ភាព ត្រូវបញ្ជាក់ពីកាលៈទេសៈ និងមូលហេតុនៃការស្លាប់ និងទីកន្លែងដែលបញ្ជូនសាកសពទៅ

(ជ) កាលបរិច្ឆេទ និងពេលវេលានៃការដោះលែង ឬការផ្ទេរទៅមន្ទីរឃុំឃាំងមួយទៀត គោលដៅ និងអាជ្ញាធរទទួលខុសត្រូវចំពោះការផ្ទេរនោះ ។

## មាត្រា ១៨ :

ស្របតាមមាត្រា១៩និងមាត្រា២០ រដ្ឋភាគីនីមួយៗត្រូវធានាចំពោះជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងព័ត៌មាននេះ ដូចជា សាច់ញាតិជនដែលត្រូវគេដកហូតសេរីភាព តំណាង ឬមេធាវីរបស់គេ អាចទទួលបានយ៉ាងហោចណាស់នូវព័ត៌មាន ដូចខាងក្រោមនេះ :

(ក) អាជ្ញាធរដែលបានបញ្ជាឱ្យធ្វើការដកហូតសេរីភាព

(ខ) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលជននោះត្រូវបានដកហូតសេរីភាព និងត្រូវបានទទួលឱ្យចូលក្នុងកន្លែងដកហូតសេរីភាព

(គ) អាជ្ញាធរទទួលខុសត្រូវគ្រប់គ្រងការដកហូតសេរីភាព

(ឃ) ទីកន្លែងនៃជនដែលត្រូវគេដកហូតសេរីភាព រួមទាំងក្នុងករណីនៃការផ្ទេរទៅកន្លែងដកហូតសេរីភាពមួយទៀត គោលដៅ និងអាជ្ញា

ធរទទួលខុសត្រូវចំពោះការផ្ទេរនោះ។

(ង) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដោះលែង

(ច) សមាសធាតុទាក់ទងនឹងស្ថានភាពសុខភាព របស់ជនដែលត្រូវគេដកហូតសេរីភាព

(ឆ) ក្នុងករណីមរណៈភាពក្នុងអំឡុងពេលនៃការដកហូតសេរីភាព ត្រូវបញ្ជាក់ពីកាលៈទេសៈ និងមូលហេតុនៃការស្លាប់ និងទីកន្លែងដែលបញ្ជូនសាកសពទៅ។

២. ត្រូវចាត់វិធានការសមស្រប ប្រសិនបើចាំបាច់ ដើម្បីការពារជនទាំងឡាយ ដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ក៏ដូចជាជនទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ពីការតាមព្យាបាទ ការបំភិតបំភ័យ ឬការដាក់ទណ្ឌកម្ម ដោយសារតែការស្វែងរកព័ត៌មានពាក់ព័ន្ធ នឹងជនដែលត្រូវគេដកហូតសេរីភាព។

## មាត្រា ១៩ :

ព័ត៌មានផ្ទាល់ខ្លួន រួមទាំងទិន្នន័យវិជ្ជសាស្ត្រ និងហ្សែន ដែលប្រមូលបាន និង/ឬបានបញ្ជូនក្នុងក្របខ័ណ្ឌនៃការស្វែងរកជនបាត់ខ្លួនណាម្នាក់ មិនត្រូវបានប្រើប្រាស់ ឬអោយប្រយោជន៍សំរាប់គោលបំណងណាផ្សេង ក្រៅពីការស្វែងរកជនបាត់ខ្លួននោះឡើយ។ ការនេះមិនត្រូវឱ្យប៉ះពាល់ ដល់ការប្រើប្រាស់ព័ត៌មានបែបនេះ ក្នុងចំណាត់ការព្រហ្មទណ្ឌ ស្តីពីបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ឬការអនុវត្តន៍សិទ្ធិទាមទារសំណងជំងឺចិត្តឡើយ។

ការប្រមូល ការចាត់ការ ការប្រើប្រាស់ និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួន រួមទាំងទិន្នន័យវិជ្ជសាស្ត្រ និងហ្សែន មិនត្រូវរំលោភ ឬមានឥទ្ធិពលនៃការរំលោភសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន ឬសេចក្តីថ្លៃថ្នូរជាមនុស្សនៃបុគ្គលណាមួយឡើយ ។

## *មាត្រា ២០ :*

១. ក្នុងករណីដែលជនណាម្នាក់ត្រូវបានការពារដោយច្បាប់ ហើយការដកហូតសេរីភាព ស្ថិតក្រោមការត្រួតពិនិត្យដោយតុលាការ សិទ្ធិទទួលព័ត៌មានដែលមានចែងក្នុងមាត្រា១៨ អាចត្រូវបានរិតត្បិត ផ្អែកលើករណីពិសេស ប្រសិនបើចាំបាច់បំផុត និងមានចែងដោយច្បាប់ ហើយប្រសិនបើ-ការបញ្ជូនព័ត៌មាន អាចប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិឯកជន ឬសុវត្ថិភាពបុគ្គល បង្កឧបសគ្គដល់ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ឬចំពោះហេតុផលស្រដៀងគ្នាដទៃទៀត អនុលោមតាមច្បាប់ និងស្របតាមច្បាប់អន្តរជាតិ ជាធរមាន ហើយស្របតាមគោលដៅនៃអនុសញ្ញានេះ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការរិតត្បិតសិទ្ធិទទួលព័ត៌មានដែលមានចែងក្នុងមាត្រា១៨ ដែលបង្កើតបានជាទង្វើដែលមានចែងក្នុងមាត្រា២ ឬរំលោភលើមាត្រា១៧ កថាខណ្ឌ១ ឡើយ ។

២. ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការគិតគូរពីភាពស្របច្បាប់នៃការដកហូតសេរីភាពបុគ្គល រដ្ឋភាគី ត្រូវធានាការពារជនទាំងឡាយដែលមាន-ចែងក្នុងមាត្រា១៨ កថាខណ្ឌ១ នូវសិទ្ធិទទួលបានការដោះស្រាយតាមផ្លូវ

តុលាការភ្លាមៗ និងមានប្រសិទ្ធភាព ជាមធ្យោបាយក្នុងការទទួលបានព័ត៌មាន ដែលមានចែងក្នុងមាត្រា១៨ កថាខ័ណ្ឌ១ ដោយមិនមានការពន្យាពេល ។ សិទ្ធិទទួលបានការដោះស្រាយនេះ មិនអាចត្រូវបានព្យួរ ឬរិតត្បិតទោះជាក្នុងករណីណាក៏ដោយ ។

## ***មាត្រា ២១ :***

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា ជនដែលគេដកហូតសេរីភាព ត្រូវបានដោះលែងក្នុងលក្ខណៈមួយដែលអនុញ្ញាតឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ ដែលអាចជឿបានថា ពួកគេពិតជាត្រូវបានដោះលែងប្រាកដមែន ។ រដ្ឋភាគីនីមួយៗ ក៏ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាបូរណភាពរូបកាយរបស់បុគ្គលទាំងនេះ និងលទ្ធភាពក្នុងការអនុវត្តន៍សិទ្ធិរបស់ពួកគេយ៉ាងពេញលេញ នៅពេលដោះលែងឱ្យមានសេរីភាព ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចណាមួយ ដែលជនទាំងនេះ អាចស្ថិតក្រោមច្បាប់ជាតិ ។

## ***មាត្រា ២២ :***

ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា៦ រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងដាក់ទណ្ឌកម្ម ចំពោះទង្វើដូចខាងក្រោមនេះ :

(ក) ការពន្យាពេល ឬការរំខានដល់ការដោះស្រាយដែលមានចែងក្នុងមាត្រា១៧ កថាខ័ណ្ឌ២(ច) និងមាត្រា២០ កថាខ័ណ្ឌ២

(ខ) ការខកខាន មិនបានកត់ត្រា អំពីការដកហូតសេរីភាពបុគ្គលណាម្នាក់ ឬការកត់ត្រាព័ត៌មានណាមួយ ដែលមន្ត្រីទទួលខុសត្រូវចំពោះបញ្ជីផ្លូវការ បានដឹង ឬគួរតែបានដឹងថាមិនពិត ។

(គ) ការបដិសេធមិនព្រមផ្តល់ព័ត៌មាន អំពីការដកហូតសេរីភាព-បុគ្គលណាម្នាក់ ឬការផ្តល់ព័ត៌មានមិនពិត ទោះជាបានបំពេញសេចក្តីតម្រូវតាមផ្លូវច្បាប់ឱ្យផ្តល់ព័ត៌មាននោះក៏ដោយ ។

***មាត្រា ២៣ :***

១. រដ្ឋភាគីនីមួយៗ ត្រូវធានាឱ្យមានការបណ្តុះបណ្តាលបុគ្គលិកប្រតិបត្តិច្បាប់ បុគ្គលិកស៊ីវិល ឬយោធា បុគ្គលិកពេទ្យ មន្ត្រីសាធារណៈ និងអ្នកដទៃទៀត ដែលអាចចូលរួមក្នុងការឃុំគ្រង ឬការប្រព្រឹត្តទៅលើជនណាម្នាក់ ដែលត្រូវគេដកហូតសេរីភាព រួមទាំងការអប់រំ និងព័ត៌មានចាំបាច់អំពីបទបញ្ញត្តិពាក់ព័ន្ធ នៃអនុសញ្ញានេះ ដើម្បី :

(ក) បង្ការការជាប់ពាក់ព័ន្ធនៃមន្ត្រីទាំងនេះក្នុងការបាត់ខ្លួន ដោយបង្ខំ

(ខ) បញ្ជាក់ពីសារសំខាន់នៃការបង្ការ និងការស៊ើបអង្កេតករណីនៃការបាត់ខ្លួនដោយបង្ខំ

(គ) ធានាថាសេចក្តីត្រូវការជាបន្ទាន់ដើម្បីដោះស្រាយករណីនៃការបាត់ខ្លួនដោយបង្ខំត្រូវបានទទួលស្គាល់ ។

២. រដ្ឋភាគីនីមួយៗ ត្រូវធានាថា បញ្ជា ឬសេចក្តីណែនាំដែលបានចេញ អនុញ្ញាត ឬជំរុញឱ្យមានការបាត់ខ្លួនដោយបង្ខំ ត្រូវបានហាមឃាត់ ។

រដ្ឋភាគីនីមួយៗត្រូវធានាថា ជនណាម្នាក់ដែលបដិសេធមិនគោរពតាមបញ្ជានេះ មិនត្រូវបានផ្តន្ទាទោសឡើយ ។

៣. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា ជនទាំងឡាយដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ដែលមានហេតុផលអាចជឿបានថា ការបាត់ខ្លួនដោយបង្ខំបានកើតឡើង ឬបានគ្រោងរាយការណ៍អំពីបញ្ហានេះ ទៅថ្នាក់លើរបស់ខ្លួន ហើយបើសិនជាចាំបាច់ ទៅអាជ្ញាធរ ឬស្ថាប័នសមស្របដែលត្រូវបានប្រគល់អំណាចឱ្យពិនិត្យ ឬដោះស្រាយករណីនេះ ។

## *មាត្រា ២៤ :*

១. សំរាប់គោលបំណងនៃអនុសញ្ញានេះ " ជនរងគ្រោះ " សំដៅដល់ជនបាត់ខ្លួន និងបុគ្គលណាម្នាក់ដែលរងការឈឺចាប់ដោយផ្ទាល់ពីការបាត់ខ្លួនដោយបង្ខំនេះ ។

២. ជនរងគ្រោះម្នាក់ៗ មានសិទ្ធិដឹងការពិតអំពីកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ ភាពជឿនលឿន និងលទ្ធផលនៃការស៊ើបអង្កេត និងជោគវាសនារបស់ជនបាត់ខ្លួន ។ រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្របចំពោះករណីនេះ ។

៣. រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីស្វែងរកកំណត់ទីកន្លែងនិងដោះលែងជនបាត់ខ្លួន ហើយក្នុងករណីមរណៈភាព ត្រូវតំកល់សពការគោរព និងការបញ្ជូនសាកសពទៅប្រទេសខ្លួនវិញ ។

៤. រដ្ឋភាគីនីមួយៗ ត្រូវធានានៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួនថា ជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ មានសិទ្ធិទទួលបានសំណងជម្ងឺចិត្ត និងសំណងការខូតខាតគ្រប់គ្រាន់ ត្រឹមត្រូវ និងភ្លាមៗ។

៥. សិទ្ធិទទួលបានសំណងជម្ងឺចិត្ត មានចែងក្នុងកឋាខ័ណ្ឌ៤នៃមាត្រានេះ រួមទាំងការខូចខាតខាងសំភារៈ និងស្មារតី ហើយប្រសិនជាសមស្រប ទម្រង់ផ្សេងៗ នៃការជួសជុលការខូចខាតដូចជា ៈ

(ក) បដិទាន

(ខ) ការស្តារសម្បទា

(គ) ការធ្វើឱ្យពេញចិត្ត រួមមានការស្តារកិត្តិយស និងសេចក្តីថ្លៃថ្នូរ

(ឃ) ការធានាមិនឱ្យកើតមានជាថ្មី

៦. ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ច ដើម្បីបន្តការស៊ើបអង្កេតរហូតដល់បញ្ជាក់ច្បាស់ពីជោគវាសនាជនបាត់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្រប ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់នៃជនបាត់ខ្លួនដែលគេមិនទាន់បានបញ្ជាក់ច្បាស់ពីជោគវាសនា និងគ្រួសាររបស់ខ្លួន នៅក្នុងវិស័យមួយចំនួន ដូចជាសុខមាលភាពសង្គម បញ្ហាហិរញ្ញវត្ថុ ច្បាប់គ្រួសារ និងសិទ្ធិលើទ្រព្យសម្បត្តិ។

៧. រដ្ឋភាគីនីមួយៗ ត្រូវធានាការពារសិទ្ធិបង្កើត និងចូលរួមដោយសេរីក្នុងអង្គការ និងសមាគមពាក់ព័ន្ធដោយការព្យាយាមបង្កើតកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ និងជោគវាសនារបស់ជនបាត់ខ្លួន និងដើម្បីជួយជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ។

***មាត្រា ២៥ :***

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនចំពោះ:

(ក) ការដកចេញដោយខុសច្បាប់ នូវកុមារទាំងឡាយ ដែលស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ កុមារដែលឪពុក ម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ ស្ថិតក្នុងការបាត់ខ្លួនដោយបង្ខំ ឬកុមារដែលកើតនៅក្នុងអំឡុងពេលនៃការចាប់ខ្លួនម្តាយ ក្រោមការបាត់ខ្លួនដោយបង្ខំ។

(ខ) ការក្លែងបន្លំ ការលាក់បាំង ឬការបំផ្លិចបំផ្លាញឯកសារ ដែលបង្ហាញពីអត្តសញ្ញាណពិតប្រាកដរបស់កុមារ ដូចមានចែងក្នុងអនុកឋាខ័ណ្ឌ (ក) ខាងលើ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីស្វែងរក និងកំណត់អត្តសញ្ញាណកុមារដែលមានចែងក្នុងកឋាខ័ណ្ឌ១ (ក) នៃមាត្រានេះ ហើយត្រូវបញ្ជូនកុមារទាំងនោះ ទៅឱ្យគ្រួសារដើមរបស់គេវិញ ស្របតាម-នីតិវិធីច្បាប់ និងកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន។

៣. រដ្ឋភាគី ត្រូវជួយគ្នាក្នុងការស្វែងរកការកំណត់អត្តសញ្ញាណ និងទីកន្លែងកុមារ ដូចមានចែងក្នុងកឋាខ័ណ្ឌ១ (ក) នៃមាត្រានេះ។

៤. ដោយសារតែសេចក្តីត្រូវការការពារឧត្តមប្រយោជន៍កុមារ ដូចមានចែងក្នុងកថាខ័ណ្ឌ១(ក) នៃមាត្រានេះ និងសិទ្ធិកុមារក្នុងការរក្សា ឬដើម្បីកំណត់ជាថ្មីនូវអត្តសញ្ញាណ រួមទាំងសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសាររបស់គេ ដូចបានទទួលស្គាល់ដោយច្បាប់ រដ្ឋភាគីដែលទទួលស្គាល់

ប្រព័ន្ធសុំកូន ឬទម្រង់ផ្សេងទៀតនៃការឃុំគ្រងកុមារ ត្រូវតែមាននីតិវិធីច្បាប់ជាស្រេច ដើម្បីពិនិត្យលើនីតិវិធីសុំកុមារ ឬនីតិវិធីឃុំគ្រងកុមារ ហើយប្រសិនជាសមស្រប ត្រូវធ្វើមោឃភាពការសុំ ឬការឃុំគ្រងកុមារដែលមានប្រភពមកពីការបាត់ខ្លួនដោយបង្ខំ។

៥. នៅគ្រប់ករណីទាំងអស់ ហើយជាពិសេស នៅរាល់បញ្ហាដែលទាក់ទងនឹងមាត្រានេះ ត្រូវគិតគូរមុនគេបង្អស់ អំពីឧត្តមប្រយោជន៍របស់កុមារ និងកុមារដែលអាចបង្កើតគំនិតផ្ទាល់ខ្លួន ត្រូវមានសិទ្ធិសំដែងមតិយោបល់ទាំងនោះដោយសេរី មតិយោបល់ដែលកុមារសំដែង ត្រូវធ្វើការថ្លឹងថ្លែង ទៅតាមអាយុ និងភាពចាស់ទុំរបស់កុមារនោះ។

## ភាគ ២

### *មាត្រា ២៦ :*

១. គណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ (ដែលនៅក្នុងឯកសារនេះហៅថា " គណៈកម្មាធិការ " ត្រូវបានបង្កើតឡើង ដើម្បីបំពេញមុខងារដែលមានចែងក្នុងអនុសញ្ញានេះ។ គណៈកម្មាធិការនេះ ត្រូវមានអ្នកជំនាញការដប់រូប ដែលមានសីលធម៌ខ្ពស់ និងសមត្ថភាពដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស ដែលត្រូវបំរើការក្នុងសមត្ថភាពរបស់ខ្លួនផ្ទាល់ដោយឯករាជ្យ និងមិនលំអៀង។ សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសរើសដោយរដ្ឋភាគី ស្របតាមការបែងចែកតាមភូមិសាស្ត្រ ប្រកបដោយសមធម៌។ ត្រូវពិចារណាយ៉ាងត្រឹមត្រូវអំពីអត្ថប្រយោជន៍ នៃការចូល

រួម ក្នុងការងាររបស់គណៈកម្មាធិការនៃជនដែលមានបទពិសោធន៍ ផ្នែកច្បាប់ពាក់ព័ន្ធ និងតំណាងតុល្យភាពយេនឌ័រ។

២. សមាជិកគណៈកម្មាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំង ជាសំងាត់ ពីក្នុងបញ្ជីបេក្ខជនឈ្មោះដែលតែងតាំងដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន ក្នុងសម័យប្រជុំរាល់ពីរឆ្នាំម្តងរបស់រដ្ឋភាគី ដែលកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់គោលបំណងនេះ។ នៅក្នុងសម័យប្រជុំទាំងនោះ ចំនួនកូរ៉ុមគឺស្មើនឹងពីរភាគបី នៃរដ្ឋភាគីបេក្ខជនដែលត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការ គឺជាបេក្ខជនដែលបានទទួលសំលេងឆ្នោតច្រើនជាងគេ និងសំលេងគាំទ្រភាគច្រើនដាច់ខាតពីតំណាងរដ្ឋភាគីទាំងឡាយ ដែលមានវត្តមាន និងបានបោះឆ្នោត។

៣. ការបោះឆ្នោតលើកដំបូង នឹងត្រូវបានរៀបចំធ្វើមិនឱ្យលើសពីប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ។ បួនខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើលិខិតមួយច្បាប់ទៅរដ្ឋភាគី ដើម្បីអញ្ជើញរដ្ឋភាគីទាំងនេះ ឱ្យតែងតាំងឈ្មោះបេក្ខជនរបស់ខ្លួនក្នុងរយៈពេលបីខែ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីមួយ តាមលំដាប់តួអក្ខរក្រមនៃបេក្ខជនឈ្មោះទាំងអស់ ដោយបញ្ជាក់ប្រាប់ពីរដ្ឋភាគីដែលបានតែងតាំង ហើយត្រូវបញ្ជូនបញ្ជីឈ្មោះនេះ ទៅរដ្ឋភាគីទាំងអស់។

៤. សមាជិកគណៈកម្មាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំង សំរាប់អាណត្តិមួយ ដែលមានរយៈពេលបួនឆ្នាំ។ សមាជិកទាំងនោះ ត្រូវមានសិទ្ធិ

ឈរឈ្មោះអោយគេបោះឆ្នោតជាថ្មីបានម្តងទៀត ។ ទោះជាយ៉ាងណាក៏ដោយ អាណត្តិរបស់សមាជិកប្រាំរូប ដែលជាប់ឆ្នោតក្នុងការបោះឆ្នោតលើកទីមួយ ត្រូវបញ្ចប់នៅខាងចុងឆ្នាំទីពីរ ។ ភ្លាម១បន្ទាប់ពីការបោះឆ្នោតលើកទីមួយ ឈ្មោះបេក្ខជនទាំងប្រាំរូបនេះ ត្រូវបានជ្រើសរើសដោយប្រធានអង្គប្រជុំ ដូចមានចែងក្នុងកឋាខ័ណ្ឌ២ នៃមាត្រានេះ ។

៥. ប្រសិនជាសមាជិកណាម្នាក់នៃគណៈកម្មាធិការនេះ ទទួលមរណៈភាព ឬលាឈប់ពីការងារ ឬដោយមូលហេតុដទៃទៀតដែលមិនអាចបំពេញការងារឱ្យគណៈកម្មាធិការបានតទៅទៀត រដ្ឋភាគីដែលបានបញ្ជូនឈ្មោះបេក្ខជននោះ ស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងកឋាខ័ណ្ឌ១ នៃ-មាត្រានេះ ត្រូវចាត់តាំងបេក្ខជនម្នាក់ផ្សេងទៀត ពីក្នុងចំណោមជនជាតិរបស់ខ្លួន ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយមានការយល់ព្រម ពីចំនួន-ភាគច្រើននៃរដ្ឋភាគី ។ ការយល់ព្រមនេះ ត្រូវបានចាត់ទុកថាបានទទួល បើពុំនោះទេ ត្រូវមានចំនួនពាក់កណ្តាល ឬច្រើនជាងពាក់កណ្តាលនៃរដ្ឋភាគីឆ្លើយបដិសេធក្នុងរយៈពេលប្រាំមួយសប្តាហ៍ចាប់ ពីថ្ងៃដែលអគ្គលេខាធិការអង្គការសហប្រជាជាតិជូនដំណឹង ពីការស្នើសុំឱ្យធ្វើការចាត់តាំងបេក្ខជនថ្មី ។

៦. គណៈកម្មាធិការនេះ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៧. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់ឱ្យគណៈកម្មាធិការនេះ នូវមធ្យោបាយចាំបាច់ ដូចជា បុគ្គលិក មធ្យោបាយ សំរាប់បំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំលើកដំបូងនៃគណៈកម្មាធិការនេះ ។

៨.សមាជិកគណៈកម្មាធិការនេះត្រូវមានសិទ្ធិប្រើប្រាស់មធ្យោបាយបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាអ្នកជំនាញការ បំពេញបេសកកម្មសំរាប់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធនៃអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ។

៩. រដ្ឋភាគីនីមួយៗ ត្រូវសហការជាមួយគណៈកម្មាធិការនេះ និង-ជួយសមាជិករបស់គណៈកម្មាធិការ ក្នុងការបំពេញអាណត្តិរបស់ខ្លួន ទៅ-តាមទំហំការងាររបស់គណៈកម្មាធិការ ដែលរដ្ឋភាគីបានយល់ព្រម ។

## ***មាត្រា ២៧ :***

សន្និសីទរបស់រដ្ឋភាគី នឹងត្រូវប្រារព្ធធ្វើយ៉ាងឆាប់បំផុត បួនឆ្នាំ ហើយយ៉ាងយូរបំផុតប្រាំមួយឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ ដើម្បីវាយតំលៃលើការងាររបស់គណៈកម្មាធិការ និងដើម្បីសំរេច ដោយអនុលោមតាមនីតិវិធីដែលមានចែងក្នុងមាត្រា៤៤ កឋាខ័ណ្ឌ២ ថាតើសមស្រប ត្រូវបញ្ជូនទៅស្ថាប័នមួយផ្សេងទៀត-ដោយមិនផាត់ចោលលទ្ធភាពណាមួយ - ដើម្បីឃ្លាំមើលអនុសញ្ញានេះ ស្របតាមមុខងារដែលបានកំណត់ក្នុងមាត្រា២៨ ដល់មាត្រា៣៦ ។

## ***មាត្រា ២៨ :***

១. នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលបានផ្តល់ឱ្យដោយអនុសញ្ញានេះ គណៈកម្មាធិការ ត្រូវសហការជាមួយគ្រប់អង្គការ ការិយាល័យ ទីភ្នាក់ងារឯកទេសដែលពាក់ព័ន្ធ និងមូលនីធិអង្គការសហប្រជាជាតិ ជាមួយស្ថាប័ន

សន្ធិសញ្ញា ដែលបង្កើតឡើងដោយលិខិតុបករណ៍អន្តរជាតិ ជាមួយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ និងជាមួយអង្គការ ឬស្ថាប័នអន្តររដ្ឋាភិបាល ក្នុងតំបន់ដែលពាក់ព័ន្ធ ក៏ដូចជា ជាមួយស្ថាប័ន ទីភ្នាក់ងារ ឬការិយាល័យរដ្ឋទាំងអស់ដែលពាក់ព័ន្ធ ដែលធ្វើការដើម្បីការពារជនគ្រប់រូប ប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ។

២.នៅពេលបំពេញអាណត្តិរបស់ខ្លួន គណៈកម្មាធិការ ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នសន្ធិសញ្ញាដទៃទៀត ដែលបានបង្កើតឡើងដោយលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេស គណៈកម្មាធិការសិទ្ធិមនុស្ស ដែលបង្កើតឡើងដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងគោលបំណងធានា ភាពស៊ីសង្វាក់គ្នានៃការសង្កេត និងការផ្តល់អនុសាសន៍របស់ខ្លួន។

***មាត្រា ២៩ :***

១. រដ្ឋភាគីនីមួយៗ ត្រូវបញ្ជូនទៅគណៈកម្មាធិការនេះ តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវរបាយការណ៍មួយ ស្តីពីការចាត់វិធានការរបស់ខ្លួន ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់រដ្ឋភាគីពាក់ព័ន្ធ។

២. អគ្គលេខាធិការអង្គការអង្គការសហប្រជាជាតិ ត្រូវផ្ញើរបាយការណ៍នេះ ទៅរដ្ឋភាគីទាំងអស់។

៣. របាយការណ៍នីមួយៗ ត្រូវបានពិចារណាដោយគណៈកម្មាធិការនេះ ដែលត្រូវធ្វើការផ្តល់មតិ ការសង្កេត ឬអនុសាសន៍ តាមការសមស្រប ។ ការផ្តល់មតិ ការសង្កេត ឬអនុសាសន៍ ត្រូវបានបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដែលរដ្ឋភាគីនោះ ត្រូវឆ្លើយតបវិញតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់គណៈកម្មាធិការ ។

៤. គណៈកម្មាធិការ ក៏អាចស្នើសុំទៅរដ្ឋភាគីនានា ឱ្យផ្តល់ព័ត៌មានបន្ថែមស្តីពីការអនុវត្តន៍សន្ធិសញ្ញានេះ ។

## មាត្រា ៣០ :

១. ការស្នើសុំឱ្យស្វែងរកជនបាត់ខ្លួន អាចត្រូវបានបញ្ជូនទៅគណៈកម្មាធិការនេះ ជាបញ្ហាបន្ទាន់ ដោយសាច់ញាតិជនបាត់ខ្លួន ឬតំណាងស្របច្បាប់ មេធាវីរបស់គេ ឬជនណាម្នាក់ ដែលទទួលបានការអនុញ្ញាតពីសាច់ញាតិ ជនបាត់ខ្លួន ក៏ដូចជា ដោយជនណាម្នាក់ផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ។

២. ប្រសិនបើគណៈកម្មាធិការនេះយល់ថា ការស្នើឱ្យចាត់វិធានការបន្ទាន់ ត្រូវបានបញ្ជូនមកស្របតាមកថាខ័ណ្ឌ១ នៃមាត្រានេះ :

(ក) មិនបង្ហាញថា គ្មានមូលហេតុត្រឹមត្រូវ

(ខ) មិនមានការរំលោភលើសិទ្ធិនៃការដាក់ពាក្យសុំនេះ

(គ) បានបង្ហាញយ៉ាងត្រឹមត្រូវហើយដល់ស្ថាប័នមានសមត្ថកិច្ច នៃរដ្ឋភាគីពាក់ព័ន្ធ ដូចជាស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត ដែលលទ្ធភាពបែបនេះអាចមាន

(ឃ) មិនមានវិសមិតភាពជាមួយបទបញ្ញត្តិនៃអនុសញ្ញានេះ ហើយ

(ង) បញ្ហាដដែលនេះ មិនត្រូវបានពិនិត្យ ក្រោមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ ដែលមានចរិតលក្ខណៈដូចគ្នា

គណៈកម្មាធិការ ត្រូវស្នើទៅរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្តល់ឱ្យខ្លួន នូវព័ត៌មានស្តីពីស្ថានភាពជនដែលគេស្វែងរក នៅក្នុងអំឡុងពេលមួយ ដែលគណៈកម្មាធិការបានកំណត់។

៣. ចំពោះព័ត៌មានដែលបានផ្តល់ដោយរដ្ឋភាគីពាក់ព័ន្ធ ស្របតាម-កថាខ័ណ្ឌ២នៃមាត្រានេះ គណៈកម្មាធិការ អាចបញ្ជូនអនុសាសន៍ ទៅរដ្ឋភាគីនោះ រួមទាំងការស្នើឱ្យរដ្ឋភាគីនោះ ចាត់វាល់វិធានការចាំបាច់ រួមទាំងវិធានការបណ្តោះអាសន្ន ដើម្បីកំណត់កន្លែង និងការពារសាម៉ីជន ស្របតាមអនុសញ្ញានេះ ហើយត្រូវជូនដំណឹងទៅគណៈកម្មាធិការ នៅក្នុងអំឡុងពេលមួយដែលបានកំណត់អំពីវិធានការដែលបានធ្វើ ដោយគិតគូរពីភាពបន្ទាន់ នៃស្ថានការណ៍។ គណៈកម្មាធិការនេះ ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំចាត់វិធានការបន្ទាន់ អំពីអនុសាសន៍របស់ខ្លួន និងអំពីព័ត៌មាន ដែលបានផ្តល់ឱ្យគណៈកម្មាធិការ ដោយរដ្ឋភាគី នៅពេលដែលខ្លួនបានទទួល។

៤. គណៈកម្មាធិការ ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើការជាមួយរដ្ឋភាគីពាក់ព័ន្ធ រហូតដល់ដរាបណាដែលគេមិនទាន់បញ្ជាក់ច្បាស់អំពីជោគវាសនារបស់ជនដែលគេស្វែងរក។ គណៈកម្មាធិការ ត្រូវបន្តជូនដំណឹង ទៅអ្នកដាក់ពាក្យសុំ។

## មាត្រា ៣១ :

១. នៅពេលផ្តល់សច្ចាប័ន ឬនៅពេលណា ក្រោយពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះក៏ដោយ រដ្ឋភាគី អាចប្រកាសថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិចារណាលើពាក្យបណ្តឹង របស់បុគ្គល ឬក្នុងនាមបុគ្គល ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលអះអាងថា ជាជនរងគ្រោះដោយការរំលោភពីរដ្ឋភាគីនេះ លើបទបញ្ញត្តិនៃអនុសញ្ញានេះ។ គណៈកម្មាធិការនេះ មិនត្រូវទទួលយកពាក្យបណ្តឹងណាដែលពាក់ព័ន្ធនឹងរដ្ឋភាគីដែលមិនបានធ្វើការប្រកាសនេះឡើយ។

២. គណៈកម្មាធិការ ត្រូវចាត់ទុកបណ្តឹងនេះ ថាមិនអាចទទួលយកបាន ប្រសិនជា :

(ក) បណ្តឹងអាណាមិក

(ខ) បណ្តឹងបង្កើតឱ្យមានការរំលោភសិទ្ធិនៃការដាក់ពាក្យបណ្តឹង ឬមិនស្របនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ

(គ) បញ្ហាដដែលនេះ កំពុងពិនិត្យក្រោមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិដែលមានចរិតលក្ខណៈដូចគ្នា ឬប្រសិនបើ

(ឃ) មិនទាន់ប្រើអស់ដំណោះស្រាយដែលមាន ប្រសិទ្ធភាពក្នុងស្រុក។ មិនត្រូវយកវិធាននេះមកប្រើទេ ប្រសិនបើការប្រើដំណោះស្រាយ-នេះ ត្រូវបានអូសបន្លាយពេលយូរ ដោយមិនសមហេតុផល។

៣. ប្រសិនបើគណៈកម្មាធិការយល់ឃើញថា បណ្តឹងនេះបំពេញតាមតម្រូវការដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ គណៈកម្មាធិការត្រូវបញ្ជូនពាក្យបណ្តឹងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីស្នើឱ្យរដ្ឋភាគីនោះផ្តល់សេចក្តីសង្កេត និងការផ្តល់មតិ ក្នុងរយៈពេលមួយដែលគណៈកម្មាធិការនេះបានកំណត់។

៤. នៅគ្រប់ពេល បន្ទាប់ពីទទួលពាក្យបណ្តឹង និងនៅមុនឈានដល់ការសំរេចលើអង្គសេចក្តី គណៈកម្មាធិការ អាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធដើម្បីធ្វើការពិចារណាជាបន្ទាន់លើការស្នើសុំឱ្យរដ្ឋភាគីចាត់វិធានការបណ្តោះអាសន្ន តាមការចាំបាច់ ដើម្បីបញ្ចៀសលទ្ធភាពនៃការមិនចេញសំណងការខូចខាតទៅជនរងគ្រោះដោយការរំលោភបំពាន។ ប្រសិនបើគណៈកម្មាធិការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ការនេះមិនចាត់ទុកថា ជាការសំរេចទទួលយក ឬសំរេចលើអង្គសេចក្តីនៃបណ្តឹងឡើយ។

៥. គណៈកម្មាធិការ ត្រូវប្រជុំជាសំងាត់ នៅពេលពិនិត្យពាក្យបណ្តឹង ក្រោមមាត្រានេះ។ គណៈកម្មាធិការ ត្រូវជូនដំណឹងទៅម្ចាស់បណ្តឹងអំពីចំលើយដែលរដ្ឋភាគីពាក់ព័ន្ធបានផ្តល់ឱ្យ ។នៅពេលដែលគណៈកម្មាធិការសំរេចបញ្ចប់នីតិវិធី គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួនទៅរដ្ឋភាគី និងទៅម្ចាស់បណ្តឹង។

## *មាត្រា ៣២ :*

រដ្ឋភាគីនៃអនុសញ្ញានេះ អាចប្រកាសគ្រប់ពេលវេលាថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដើម្បីទទួល និងពិចារណាបណ្តឹងដែល

ក្នុងនោះ រដ្ឋភាគីអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ច របស់ខ្លួន ក្រោមអនុសញ្ញានេះទេ។ គណៈកម្មាធិការ មិនទទួលពាក្យបណ្តឹង ទាំងឡាយណា ដែលពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើការប្រកាសនេះ ឬ ពាក្យបណ្តឹងពីរដ្ឋភាគីដែលមិនបានធ្វើការប្រកាសនេះឡើយ។

## *មាត្រា ៣៣ :*

១. ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មានដែលអាចទុកចិត្តបាន បញ្ជាក់ថា រដ្ឋភាគីមួយកំពុងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញានេះ ក្រោយ ពីបានពិគ្រោះយោបល់ជាមួយរដ្ឋភាគីពាក់ព័ន្ធ ហើយគណៈកម្មាធិការ អាច ស្នើឱ្យសមាជិករបស់ខ្លួនម្នាក់ ឬច្រើននាក់ ទៅធ្វើទស្សនកិច្ច ហើយរាយ ការណ៍មកគណៈកម្មាធិការវិញ ដោយមិនមានការពន្យាពេល។

២. គណៈកម្មាធិការត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋភាគី ពាក់ព័ន្ធ អំពីចេតនារបស់ខ្លួន ដើម្បីរៀបចំធ្វើទស្សនកិច្ច ដោយបញ្ជាក់ប្រាប់ អំពីសមាសភាពគណៈប្រតិភូនិងអំពីគោលបំណងនៃការធ្វើទស្សនកិច្ចនោះ។ រដ្ឋភាគីត្រូវឆ្លើយតបមកគណៈកម្មាធិការវិញក្នុងអំឡុងពេលមួយសមស្រប។

៣. នៅពេលមានការស្នើសុំពីរដ្ឋភាគី ដោយបញ្ជាក់ហេតុផលត្រឹម ត្រូវ គណៈកម្មាធិការអាចសំរេចលើកពេល ឬលប់ចោលការធ្វើទស្សនកិច្ច របស់ខ្លួន។

៤. ប្រសិនបើរដ្ឋភាគីយល់ព្រមចំពោះការធ្វើទស្សនកិច្ចនេះ គណៈ កម្មាធិការ និងរដ្ឋភាគីពាក់ព័ន្ធត្រូវធ្វើការរួមគ្នា ដើម្បីកំណត់របៀបនៃការ

ធ្វើទស្សនកិច្ច ហើយរដ្ឋភាគីត្រូវផ្តល់ឱ្យគណៈកម្មាធិការ នូវគ្រប់មធ្យោបាយចាំបាច់ សំរាប់ឱ្យការបំពេញទស្សនកិច្ចនេះបានជោគជ័យ ។

៥. ក្រោយពីបានបំពេញទស្សនកិច្ចរួច គណៈកម្មាធិការត្រូវបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ នូវសេចក្តីសង្កេត និងអនុសាសន៍របស់ខ្លួន ។

## *មាត្រា ៣៤ :*

ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មាន ដែលខ្លួនយល់ថា មានតម្រុយច្បាស់លាស់ ថាការបាត់ខ្លួនដោយបង្ខំ បាននឹងកំពុងកើតមានជាទូទៅ ឬជាប្រព័ន្ធនៅលើទឹកដីស្ថិតក្រោមយុត្តាធិការរបស់រដ្ឋភាគីមួយ បន្ទាប់ពីស្វែងរកព័ត៌មានពាក់ព័ន្ធពីរដ្ឋភាគីសាមីអំពីស្ថានការណ៍នោះហើយ គណៈកម្មាធិការ អាចលើកយកបញ្ហានេះជាបន្ទាន់ប្រាប់ដល់មហាសន្និបាតអង្គការសហប្រជាជាតិ តាមរយៈអគ្គលេខាអង្គការសហប្រជាជាតិ ។

## *មាត្រា ៣៥ :*

១. គណៈកម្មាធិការ ត្រូវមានសមត្ថកិច្ចដាច់មុខ ចំពោះការបាត់ខ្លួនដោយបង្ខំ ដែលបានចាប់ផ្តើមអនុវត្ត បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ ។

២. ប្រសិនបើរដ្ឋមួយក្លាយជាភាគីនៃអនុសញ្ញានេះ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ កាតព្វកិច្ចរបស់រដ្ឋនោះ ចំពោះគណៈកម្មាធិការត្រូវទាក់ទងតែចំពោះការបាត់ខ្លួនដោយបង្ខំ ដែលបានចាប់ផ្តើម បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់រដ្ឋសាមីនោះ ។

***មាត្រា ៣៦ :***

១. គណៈកម្មាធិការ ត្រូវដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនតាមអនុសញ្ញានេះ ទៅរដ្ឋភាគីនានា និងទៅមហាសន្និបាតអង្គការ សហប្រជាជាតិ ។

២. មុននឹងសេចក្តីសង្កេតលើរដ្ឋភាគីមួយ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ រដ្ឋភាគីសាមីនោះ ត្រូវបានជូនដំណឹងជាមុន ហើយត្រូវទុកពេលវេលាមួយសមស្របសំរាប់ធ្វើការឆ្លើយតបវិញ ។ រដ្ឋភាគីនេះ អាចស្នើឱ្យបោះពុម្ពផ្សាយសេចក្តីផ្តល់មតិ ឬការសង្កេតនៅក្នុងរបាយការណ៍នេះបាន ។

## ភាគ ៣

***មាត្រា ៣៧ :***

គ្មានបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះប៉ះពាល់ដល់បញ្ញត្តិទាំងឡាយណា ដែលនាំឱ្យមានការការពារជនគ្រប់រូប ពីការបាត់ខ្លួនដោយបង្ខំឡើយ ហើយបញ្ញត្តិទាំងនេះ អាចមានចែងក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី

(ខ) ច្បាប់អន្តរជាតិដែលនៅមានជាធរមានសំរាប់រដ្ឋនោះ

***មាត្រា ៣៨ :***

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា ដោយរដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ។

២. អនុសញ្ញានេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ដោយរដ្ឋសមាជិកសហប្រជាជាតិទាំងអស់។ លិខិតុបករណ៍ផ្តល់សច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចូលជាសមាជិក ដល់រដ្ឋសមាជិកទាំងអស់របស់សហប្រជាជាតិ។ ការចូលជាសមាជិក នឹងមានប្រសិទ្ធភាពទៅបាន ដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ៣៩ :

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ នៃលិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទីម្ភៃ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី២០ អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ។

## មាត្រា ៤០ :

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងទៅរដ្ឋសមា-

ជិកទាំងអស់របស់ខ្លួន និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខា ឬចូលជាសមាជិកនៃអនុសញ្ញានេះ ដូចតទៅ :

(ក) ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកតាមមាត្រា៣៨ ។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ តាម-មាត្រា៣៩ ។

***មាត្រា ៤១ :***

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិត ឬការលើកលែងណាមួយឡើយ ។

***មាត្រា ៤២ :***

១. ទំនាស់រវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ហើយដែលមិនអាចដោះស្រាយតាម-រយៈការចរចា ឬតាមនីតិវិធីដែលមានចែងច្បាស់លាស់ក្នុងអនុសញ្ញានេះបានត្រូវបញ្ជូនទៅដោះស្រាយតាមរយៈមជ្ឍតកម្ម តាមការស្នើសុំរបស់ភាគីទំនាស់ណាមួយ ។ ប្រសិនជាក្នុងអំឡុងពេល៦ខែ ចាប់ពីកាលបរិច្ឆេទ នៃការស្នើសុំដោះស្រាយតាមរយៈមជ្ឍតកម្ម ភាគីទាំងអស់ មិនអាចព្រមព្រៀងគ្នាលើការរៀបចំមជ្ឍតកម្មទេ ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាម-ការស្នើសុំរបស់ភាគីទំនាស់ណាមួយ ស្របតាមលក្ខន្តិកៈនៃតុលាការនេះ ។

២. នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុ

សញ្ញានេះ រដ្ឋមួយ អាចប្រកាសថា ខ្លួនមិនចាត់ទុកថា ជាប់កាតព្វកិច្ចតាម កឋាខ័ណ្ឌ១ នៃមាត្រានេះទេ។ រដ្ឋភាគីដទៃទៀត ក៏មិនជាប់កាតព្វកិច្ច តាម កឋាខ័ណ្ឌ១ នៃមាត្រានេះដែរ ចំពោះរដ្ឋភាគីណាដែលបានធ្វើការប្រកាស បែបនេះ។

៣. រដ្ឋភាគីណាមួយដែលបានធ្វើការប្រកាស ស្របតាមបទបញ្ញត្តិ កឋាខ័ណ្ឌ២នៃមាត្រានេះ អាចដកការប្រកាសរបស់ខ្លួនបានគ្រប់ពេល ដោយ គ្រាន់តែជូនដំណឹងនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## *មាត្រា ៤៣ :*

១. អនុសញ្ញានេះ មិនធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិនៃច្បាប់មនុស្ស ធមិអន្តរជាតិ រួមទាំងកាតព្វកិច្ចរបស់រដ្ឋភាគីចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ទាំងបួន ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមពីរនៃអនុសញ្ញា ចុះថ្ងៃទី៨ខែមិថុនា ឆ្នាំ១៩៧៧ ឬប៉ះពាល់ដល់ឱកាសដែលមានសំរាប់រដ្ឋភាគី ណាមួយ ដែលអនុញ្ញាតឱ្យគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ទៅធ្វើ ទស្សនកិច្ច នៅកន្លែងឃុំឃាំងក្នុងស្ថានការណ៍ ដែលមិនស្ថិតក្រោមច្បាប់ មនុស្សធមិអន្តរជាតិ។

## *មាត្រា ៤៤ :*

១. រដ្ឋភាគីណាមួយនៃអនុសញ្ញានេះ អាចស្នើធ្វើវិសោធនកម្ម និង- ដាក់សេចក្តីស្នើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខា ធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មនេះ ទៅរដ្ឋ

ភាគីនៃអនុសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគី បញ្ជាក់ថាតើ យល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោត លើសេចក្តីស្នើវិសោធនកម្មនេះឬទេ។ ប្រសិនបើក្នុងអំឡុងពេលបួនខែ ចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសំណើនេះ មានសម្លេង ១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ប្រកាសយល់ព្រមឱ្យមានសន្និសីទនេះ អគ្គលេខាធិការអង្គការសហប្រជា-ជាតិ ត្រូវកោះប្រជុំសន្និសីទនេះ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។

២. គ្រប់វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើន ពីរភាគបីនៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតនៅឯសន្និសីទ ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិ ដាក់ជូនរដ្ឋភាគីទាំងអស់ ដើម្បីសុំការយល់ព្រម។

៣. វិសោធនកម្មដែលបានអនុម័តស្របតាមកឋាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលដែលចំនួនពីរភាគបីនៃរដ្ឋភាគីនៃអនុសញ្ញានេះបានទទួលយល់ព្រមស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

៤. នៅពេលដែលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ច សំរាប់រដ្ឋភាគីទាំងឡាយដែលបានទទួលយល់ព្រមយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀត-ដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញានេះ និងវិសោធនកម្មមុនៗដែលខ្លួនបានទទួលយល់ព្រមហើយ។

***មាត្រា ៤៥ :***

១. អនុសញ្ញានេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃអនុសញ្ញានេះ ដោយមានបញ្ជាក់ពីការចម្លងតាមច្បាប់ដើម ជូនដល់រដ្ឋទាំងអស់ យោងតាមមាត្រា ៣៨ ។